# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២២០ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.០៩....ខែ.មករា..ឆ្នាំ ២០១៧

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីស្ថានភាពនៃការបំពេញបែបបទនាំចេញអង្ករប្រចាំឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា នៅរយៈពេល១២ខែ ឆ្នាំ២០១៦នេះ ស្ថានភាពនៃការនាំចេញអង្ករទៅក្រៅប្រទេសដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានដោយផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ National Phytosanitary database (NPD/GDA from 07:00/01.01.2016 to 17:00/30.12.2016) ដែលជាតួលេខនៃការនាំចេញតាមរយៈការរៀបចំវេចខ្ចប់គ្រប់ចំនួនរួចជាស្រេច និងបានឆ្លងកាត់ការត្រួតពិនិត្យភូតគាមអនាម័យដើម្បីនាំចេញមានដូចខាងក្រោម៖

**១- ស្ថានភាពនៃការនាំចេញអង្ករ៖**

- បរិមាណអង្ករនាំចេញមានចំនួន ៥៤២ ១៤៤តោន កើនឡើងចំនួន ៣ ៧៤៨ តោន (+0,៧%) លើសបរិមាណនាំចេញក្នុងឆ្នាំ២០១៥ (ដែលមានតែ ៥៣៨ ៣៩៦តោន)។ ក្នុងនោះបរិមាណនាំចេញក្នុងខែធ្នូនេះ មានចំនួន ៦២ ៤៥៥តោន ដែលមានការថយចុះចំនួន ១៩ ០២៤ តោន (-៣០,៥%) តិចជាងខែធ្នូឆ្នាំមុន (សូមបង្ហាញជូនក្នុងតារាងទី១ នៃឧបសម្ព័ន្ធ១)

- អង្ករក្រអូបគ្រប់ប្រភេទមានបរិមាណនាំចេញដល់ ៣០៦ ៩០៦ តោន ស្មើនឹង ៥៦,៦១% ដែលមានបរិមាណច្រើនជាងបរិមាណអង្ករ ស គ្រប់ប្រភេទមានចំនួន ១៨៨ ៦០៥តោន ស្មើនឹង ៣៤,៧៩% និង អង្ករចំហុយមានចំនួន ៤៦ ៦៣៣តោន ស្មើនឹង៨,៦%។ ក្នុងចំណោមអង្ករក្រអូបនោះ អង្ករផ្ការំដួល/ផ្កាម្លិះជាប្រភេទអង្ករដែលបាននាំចេញច្រើនជាងគេមានរហូតដល់ ៣១,៨៩% និងអង្ករក្រអូបចម្រុះ (សែនក្រអូប នាងសយ...) មាន ២១,៧% នៃបរិមាណអង្ករនាំចេញសរុបក្នុងឆ្នាំនេះ។ អង្ករផ្ការំដួលដែលជាពូជស្រូវផលិតឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានជាប់ចំណាត់ថ្នាក់ជាអង្ករល្អបំផុតលើពិភពលោករយៈពេល៣ឆ្នាំបន្តបន្ទាប់គ្នា ជាប្រភេទអង្ករដែលបានធ្វើការនាំចេញច្រើនជាងគេ (៥៦,៦%) ក្នុងចំណោមអង្ករក្រអូបដទៃទៀត (សូមបង្ហាញជូនក្នុងតារាងទី២នៃឧបសម្ព័ន្ធ១)

- អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន ៦៥ប្រទេស (កើនឡើងចំនួន ៥ប្រទេសធៀបនឹងឆ្នាំមុន) ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (១២៧ ៤៦០តោន) ប្រទេសបារាំងលំដាប់ទី២ (៧៨ ៣២៩តោន) ប្រទេសប៉ូឡូញលំដាប់ទី៣ (៦៤ ០៣៥តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៤ (៣៨ ៨៧៧តោន) ប្រទេសណេដឺឡែនលំដាប់ទី៥ (២៨ ៦៩០តោន) ប្រទេសប៊ែលហ្សិកលំដាប់ទី៦ (២២ ៨៨៥តោន) ប្រទេសឆេកលំដាប់ទី៧ (២២ ៨១៥តោន) ប្រទេសអ៊ីតាលីលំដាប់ទី៨ (១៨ ៦១៩តោន) ប្រទេសអង់គ្លេសលំដាប់ទី៩ (១៧ ៦៧៣តោន) និងប្រទេសអាល្លឺម៉ង់លំដាប់ទី១០ (១៦ ៦១៦តោន)។ បរិមាណអង្ករដែលនាំចេញទៅកាន់សហភាពអឺរ៉ុប ២៥ប្រទេស មានបរិមាណសរុប ៣៤១ ០៦៦តោន (៦២,៩%) ទិសដៅអាស៊ាន ៤ប្រទេស មានបរិមាណសរុប ៥៤ ៨៧០តោន (១០,១%) និងទិសដៅដទៃទៀត ៣៦ប្រទេស មានបរិមាណសរុប ១៤៦ ២០៨តោន (២៧%) (សូមបង្ហាញជូនលម្អិតក្នុងតារាងទី៣ នៃឧបសម្ព័ន្ធ)

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- ការនាំចេញអង្ករមាន៨៥ក្រុមហ៊ុន (កើន២ក្រុមហ៊ុនក្នុងខែវិច្ឆិកា) ដែលបរិមាណអង្ករនាំចេញត្រូវបាននាំមុខគេដោយៈ (ទី១). ក្រុមហ៊ុន Baitang មានចំនួន ៤៥ ៥១៦តោន (ទី២). ក្រុមហ៊ុន Crystal Rice មានចំនួន ៤៣ ៨០០ តោន (ទី៣).ក្រុមហ៊ុន Khmer Food group មានចំនួន ៤៣ ៧៩០តោន (ទី៤).ក្រុមហ៊ុន Nikoline Investment មានចំនួន ៤៣ ៥៤១តោន (ទី៥). ក្រុមហ៊ុន Amru Rice មានចំនួន ៤១ ៥០៨តោន (ទី៦). ក្រុមហ៊ុន Golden Rice មានចំនួន ៣៦ ២៦២តោន (ទី៧). ក្រុមហ៊ុន City Rice Import Export មានចំនួន ៣១ ៥០៩តោន (ទី៨).ក្រុមហ៊ុន International Rice Trading មានចំនួន ២៩ ៣៤៧តោន (ទី៩). ក្រុមហ៊ុន T.O.T មានចំនួន ២០ ០២៩តោន (ទី១០). ក្រុមហ៊ុន Signatures of Asia មានចំនួន ១៩ ២៨៤តោន។ បរិមាណអង្ករដែលនាំចេញដោយក្រុមហ៊ុនធំៗ ទាំង១០ មានចំនួនសរុបរហូតដល់ ៣៥៤ ៥៨៦តោន (៦៥,៤%) នៅពេលដែលក្រុមហ៊ុន ៧៥ ដទៃទៀតនាំចេញបានតែ ១៨៧ ៥៥៨តោន (៣៤,៦%) (សូមបង្ហាញជូនលម្អិតក្នុងតារាងទី៤នៃឧបសម្ព័ន្ធ)។

**២-សន្និដ្ឋាន**

បរិមាណអង្ករនាំចេញសរុបប្រចាំឆ្នាំ២០១៦ មានចំនួន ៥៤២ ១៤៤តោន ដែលបរិមាណនេះកើនឡើងចំនួន ៣៧៤៨តោន ស្មើនឹង+0,៧% ធៀបនឹងបរិមាណនាំចេញប្រចាំឆ្នាំ២០១៥មានតែចំនួន ៥៣៨ ៣៩៦ តោន។ កំណើនដ៏តិចតួចនាឆ្នាំនេះជាសញ្ញាគួរឱ្យបារម្ភដែលបណ្តាលមកពីការថយចុះយ៉ាងខ្លាំងចំនួន៧ខែឆ្នាំនេះ ធៀបនឹងឆ្នាំមុន ពិសេសក្នុងចន្លោះពីខែមីនាដល់ខែសីហា និងក្នុងខែធ្នូ (-៣០,៥០%)កន្លងមកនេះ។

ទោះជាយ៉ាងណា លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ ដែលជាសេ-នាធិការរបស់ក្រុមការងារទី៩ នៅតែខិតខំបន្តពង្រីកវិសាលភាពដើម្បីបំពេញតួនាទីក្នុងការបង្កើនការយល់ដឹងដល់សមត្ថកិច្ចពាក់ព័ន្ធ ក្រុមហ៊ុននាំចេញអង្ករ រោងម៉ាស៊ីនកិនស្រូវ និងកែច្នៃអង្ករ ក្រុមហ៊ុនដឹកជញ្ជូន។ល។ ដែលកំពុងមានសកម្មភាពពាក់ព័ន្ធនឹងការនាំចេញអង្ករ ក្នុងការប្រឹងប្រែងបង្កើនភាពប្រកួតប្រជែងខាងថ្លៃ និងគុណភាព តាមរយៈការកាត់បន្ថយថ្លៃដើមនៃការផលិត ការដាំដុះ ការកែច្នៃ និងការនាំចេញ ដើម្បីលើកកម្ពស់សមត្ថភាពប្រមូលទំនិញ សម្ងួត និងឃ្លាំងស្តុក និងខិតខំរកទីផ្សារនាំចេញអង្ករជាមួយប្រទេសពាក់ព័ន្ធផ្សេងៗទៀត។ ទន្ទឹមនឹងនេះ ក្រសួងបានយកចិត្តទុកដាក់បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន រួមទាំងសហគមន៍កសិកម្មផងដែរក្នុងក្របខ័ណ្ឌក្រុមការងារទី៩ ដើម្បីរិះរកវិធានការតាមភារកិច្ចក្នុងការចូលរួមដោះស្រាយរាល់បញ្ហាប្រឈមលើការធ្លាក់ចុះតម្លៃស្រូវអង្ករនៅមូលដ្ឋាន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានផែនការនិងស្ថិតិ "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

(Revised 05/01)

# ឧបសម្ព័ន្ធៈ របាយការណ៍អំពីស្ថានភាពនៃការនាំចេញអង្ករកម្ពុជាប្រចាំឆ្នាំ២០១៦

**(ANNEX: THE REPORT ON CAMBODIAN RICE EXPORT STATUS IN, 2016)**

(Base on NPD/GDA from 07:00/01.01.2016 to 17:00/30.12.2016 and all number are English punctuation)

## តារាងទី១.បរិមាណអង្ករកម្ពុជាដែលបាននាំចេញប្រចាំខែ ក្នុងឆ្នាំ ២០១២ - ២០១៦, គិតជាតោន

(Table1. Quantity of Cambodian Rice have been Exported by months of 2012-2016, in tones)

| | Month/ Year | 2012 | 2013 | 2014 | 2015 | 2016 | VARIATION |
|---|---|---|---|---|---|---|---|
| 1 | មករា (January) | 9,703 | 25,726 | 21,536 | 35,921 | 44,033 | +22.60% |
| 2 | កុម្ភៈ (February) | 14,417 | 24,089 | 27,037 | 37,676 | 51,912 | +37.80% |
| 3 | មិនា (March) | 12,310 | 45,413 | 35,757 | 75,867 | 66,275 | -14.50% |
| 4 | មេសា (April) | 15,036 | 23,276 | 35,961 | 51,719 | 39,550 | -30.80% |
| 5 | ឧសភា ( May) | 13,115 | 28,350 | 27,971 | 41,842 | 32,558 | -28.50% |
| 6 | មិថុនា (June) | 13,426 | 29,105 | 29,666 | 40,800 | 33,862 | -20.50% |
| 7 | កក្កដា (July) | 20,527 | 31,411 | 26,060 | 28,492 | 24,087 | -18.30% |
| 8 | សីហា (August) | 15,530 | 29,358 | 29,871 | 29,819 | 27,799 | -7.30% |
| 9 | កញ្ញា (September) | 15,169 | 29,395 | 35,511 | 26,969 | 41,429 | +53.60% |
| 10 | តុលា (October) | 16,967 | 28,031 | 35,418 | 39,064 | 60,016 | +53.60% |
| 11 | វិច្ឆិកា (November) | 25,189 | 37,855 | 31,137 | 48,748 | 58,168 | +19,32% |
| 12 | ធ្នូ (December) | 34,328 | 46,847 | 51,136 | 81,479 | 62,455 | -30.50% |
| | **GRAND TOTAL** | 205,717 | 378,856 | 387,061 | 538,396 | 542,144 | +0.70% |

## តារាងទី២.ប្រភេទអង្ករកម្ពុជាដែលបាននាំចេញប្រចាំឆ្នាំ ២០១៦, គិតជាតោន

(Table 2. Type of Cambodian Rice have been Exported on year 2016, in tones

| | ប្រភេទអង្ករ TYPE OF RICE | ត្រីមាស១ 1 QUARTER | ត្រីមាស២ 2 QUARTER | ត្រីមាស៣ 3 QUARTER | តុលា OCT | វិច្ឆិកា NOV | ធ្នូ DEC | សរុប (TOTAL) MT | % |
|---|---|---|---|---|---|---|---|---|---|
| | **I. អង្ករក្រអូប /JASMINE/ FRAGRANT RICE:** | | | | | | | | |
| 1 | ចម្រុះ (F.SENKRAOB, NEANG SAUY....) | 19,631 | 12,814 | 19,147 | 36,006 | 21,689 | 8,380 | 117,667 | 21.70 |
| 2 | នាងម្លិស (F. NEANG MALIS) | 3,909 | 1,697 | 353 | 1,089 | 190 | 190 | 7,428 | 1.37 |
| 3 | សូមាលី .( F. SOMALY) | 670 | 538 | 719 | 96 | 480 | 282 | 2,785 | 0.51 |
| 4 | ផ្ការំដួល /ផ្កាម្លិស/ (J.PHKA RUMDUOL/ MALIS) | 45,913 | 32,888 | 25,215 | 9,403 | 22,074 | 37,394 | 172,887 | 31.89 |
| 5 | សរីរាង្គ (J.ORGANIC) | 999 | 1,673 | 668 | 55 | 256 | 131 | 3,782 | 0.70 |
| 6 | ភ្លី . (F. PEARL) | 1,222 | 460 | 577 | 24 | 50 | 24 | 2,357 | 0.43 |
| | SUB-TOTAL | 72,344 | 50,070 | 46,679 | 46,673 | 44,739 | 46,401 | 306,906 | 56.61 |
| | **II.អង្ករសគ្រាប់វែង /WHITE LONG GRAIN RICE:** | | | | | | | | |
| 1 | ចម្រុះគ្រាប់វែង (LONG GRAIN) | 75,947 | 39,287 | 33,835 | 10,266 | 9,591 | 12,203 | 181,129 | 33.41 |
| 2 | ប្រណិតគ្រាប់វែង (PREMIUM LONG GRAIN) | 2,162 | 1,700 | 1,871 | 591 | 703 | 449 | 7,476 | 1.38 |
| | SUB-TOTAL | 78,109 | 40,987 | 35,706 | 10,857 | 10,294 | 12,652 | 188,605 | 34.79 |
| | **III.អង្ករចំហុយគ្រាប់វែង/ LONG GRAIN PABOILLED:** | | | | | | | | |
| 1 | ចំហុយគ្រាប់វែង (LONG GRAIN PABOILLED) | 11,767 | 14,913 | 10,930 | 2,486 | 3,135 | 3,402 | 46,633 | 8.60 |
| | SUB-TOTAL | 11,767 | 14,913 | 10,930 | 2,486 | 3,135 | 3,402 | 46,633 | 8.60 |
| | **GRAND TOTAL** | 162,220 | 105,970 | 93,315 | 60,016 | 58,168 | 62,455 | 542,144 | 100.00 |

## តារាងទី៣.ទិសដៅនៃការនាំចេញអង្ករកម្ពុជាប្រចាំឆ្នាំ ២០១៦, គិតជាតោន

(Table 3. Export Destination of Cambodian Rice on year 2016, in tones

| | ប្រទេសទិសដៅ<br>COUNTRY DESTINATION | ត្រីមាសទី១<br>1st QUARTER | ត្រីមាសទី២<br>2nd QUARTER | ត្រីមាសទី៣<br>3th QUARTER | តុលា<br>October | វិច្ឆិកា<br>November | ធ្នូ<br>December | សរុប<br>TOTAL |
|---|---|---|---|---|---|---|---|---|
| | **I.សមាជិកសហគមន៍អឺរ៉ុប /EUROPEAN UNION** | | | | | | | |
| 1 | FRANCE | 20,996 | 16,467 | 16,321 | 7,389 | 9,098 | 8,058 | 78,329 |
| 2 | POLAND | 18,212 | 17,952 | 15,156 | 4,831 | 3,922 | 3,962 | 64,035 |
| 3 | NETHERLAND | 8,307 | 5,792 | 4,269 | 3,126 | 3,016 | 4,180 | 28,690 |
| 4 | BELGIUM | 5,897 | 8,715 | 3,356 | 857 | 1,936 | 2,124 | 22,885 |
| 5 | CZECH REPUBLIC | 7,956 | 5,145 | 4,615 | 520 | 1,867 | 2,712 | 22,815 |
| 6 | ITALY | 5,517 | 5,166 | 2,822 | 1,453 | 1,047 | 2,614 | 18,619 |
| 7 | UNITED KINGDOM | 6,184 | 5,152 | 3,193 | 1,063 | 735 | 1,346 | 17,673 |
| 8 | GERMANY | 4,821 | 2,967 | 2,106 | 1,673 | 2,317 | 2,732 | 16,616 |
| 9 | PORTUGAL | 5,835 | 2,779 | 2,968 | 1460 | 2,524 | 722 | 16,288 |
| 10 | SPAIN | 3,074 | 2,244 | 1,461 | 217 | 232 | 320 | 7,548 |
| 11 | DENMARK | 1,608 | 1,681 | 1,635 | 375 | 558 | 562 | 6,419 |
| 12 | HUNGARY | 2,058 | 1,955 | 1,035 | 769 | 245 | 294 | 6,356 |
| 13 | SWEEDEN | 1,900 | 1,689 | 1,204 | 656 | 263 | 271 | 5,983 |
| 14 | GREECE | 3,248 | 606 | 759 | 440 | 387 | 288 | 5,728 |
| 15 | CROATIA | 1,525 | 1,225 | 925 | 125 | 550 | 550 | 4,900 |
| 16 | ROMANIA | 1,898 | 1,816 | 639 | - | 375 | - | 4,728 |
| 17 | BULGARIA | 2,273 | 274 | 650 | 150 | | 150 | 3,497 |
| 18 | LITHUANIA | 444 | 946 | 1,044 | - | 150 | 496 | 3,080 |
| 19 | LATIVA | 825 | 675 | 750 | - | 125 | - | 2,375 |
| 20 | SLOVENIA | 504 | 372 | 477 | 432 | 24 | 120 | 1,929 |
| 21 | CYPRUS | 196 | 172 | 274 | | 50 | 124 | 816 |
| 22 | AUSTRIA | 145 | 212 | 189 | 24 | 43 | - | 613 |
| 23 | ESTONIA | 250 | 50 | 0 | - | 75 | 100 | 475 |
| 24 | FINLAND | 64 | 207 | 65 | 24 | 40 | 41 | 441 |
| 25 | IRELAND | 42 | 24 | 66 | 48 | 48 | - | 228 |
| | SUB-TOTAL | **103,779** | **84,283** | **65,979** | **25,632** | **29,627** | **31,766** | **341,066** |
| | **II. សមាជិកអាស៊ាន/ASEAN MEMBER STATE** | | | | | | | |
| 1 | MALAYSIA | 8,210 | 6,299 | 5,896 | 6,486 | 6,691 | 5,295 | 38,877 |
| 2 | BRUNEI | 5,922 | 1,974 | - | - | 1,680 | 3,318 | 12,894 |
| 3 | SINGAPORE | 832 | 837 | 822 | 234 | 260 | 90 | 3,075 |
| 4 | VIETNAM | - | 21 | - | - | - | 3 | 24 |
| | SUB-TOTAL | **14,964** | **9,131** | **6,718** | **6,720** | **8,631** | **8,706** | **54,870** |
| | **III.ទិសដៅផ្សេងទៀត /OTHERS DESTINATION** | | | | | | | |
| 1 | CHINA | 37,118 | 9,906 | 17,645 | 25,277 | 17,145 | 20,369 | 127,460 |
| 2 | GABON | 2,069 | - | 823 | | 1,670 | 71 | 4,633 |
| 3 | HONG KONG | 1,130 | 342 | 655 | 1,672 | - | 632 | 4,431 |
| 4 | RUSSIAN FED | 475 | 543 | 151 | 148 | 72 | 122 | 1,511 |
| 5 | AUSTRALIA | 545 | 90 | 172 | 199 | 342 | 161 | 1,509 |
| 6 | USA | 336 | 292 | 171 | - | 285 | 162 | 1,246 |
| 7 | NEWZEALAND | 116 | 231 | 189 | 47 | 183 | - | 766 |
| 8 | IRAQ | 230 | 253 | 207 | - | - | - | 690 |
| 9 | MAYOTTE | 125 | 172 | 125 | 150 | - | 100 | 672 |
| 10 | ANGOLA | 500 | 25 | 0 | 25 | - | - | 550 |
| 11 | CANADA | 104 | 174 | 170 | - | 21 | 44 | 513 |
| 12 | TURKY | 500 | - | 0 | - | - | - | 500 |
| 13 | GATETS | - | - | - | - | - | 250 | 250 |
| 14 | SAUDI ARABIA | - | 72 | 0 | - | 48 | 72 | 192 |
| 15 | ALGERIA | - | - | 125 | - | - | - | 125 |
| 16 | SWITZERLAND | 98 | 24 | 0 | - | - | - | 122 |
| 17 | CONGO | - | 48 | 72 | - | - | - | 120 |
| 18 | JAPAN | 7 | 100 | 2 | - | - | - | 109 |
| 19 | KENYA | - | 50 | 0 | 50 | - | - | 100 |
| 20 | MALTA | - | 24 | 24 | - | 48 | - | 96 |
| 21 | GHANA | - | 19 | 38 | - | 23 | - | 80 |
| 22 | NAMIBIA | 25 | 25 | 0 | 25 | | - | 75 |
| 23 | IVORY COAST | - | - | - | - | 73 | - | 73 |
| 24 | REPUB/ DJIBOUTI | - | 72 | 0 | - | - | - | 72 |
| 25 | SENEGAL | 25 | 23 | 0 | - | - | - | 48 |
| 26 | LEBANON | 25 | - | 0 | - | - | - | 25 |
| 27 | MAURITINIA | 25 | - | 0 | - | - | - | 25 |
| 28 | BISSAU | - | 25 | 0 | - | - | - | 25 |
| 29 | UKRAINE | - | - | 25 | - | - | - | 25 |
| 30 | BENIN | - | - | - | 25 | - | - | 25 |
| 31 | ISRAEL | 24 | - | 0 | - | - | - | 24 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 32 | TAIWAN | - | 24 | 0 | - | - | - | 24 |
| 33 | CAMAROON | - | - | 24 | - | - | - | 24 |
| 34 | HAMBURG | | - | - | 24 | - | - | 24 |
| 35 | MACAU | - | 22 | 0 | - | - | - | 22 |
| 36 | UNITED ARAB EMIRATES | - | - | - | 22 | - | - | 22 |
| | SUB-TOTAL | 43,477 | 12,556 | 20,618 | 27,664 | 19,910 | 21,983 | 146,208 |
| | GRAND TOTAL | 162,220 | 105,970 | 93,315 | 60,016 | 58,168 | 62,455 | 542,144 |

## តារាងទី៤.ក្រុមហ៊ុននិងបរិមាណដែលបានធ្វើការនាំចេញអង្ករកម្ពុជាប្រចាំឆ្នាំ ២០១៦,គិតជាតោននិង%

(Table 4.Cambodian Rice Exporters and export quantity on year 2016, in tones & % share)

| | ក្រុមហ៊ុននាំចេញអង្ករ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | តុលា | វិច្ឆិកា | ធ្នូ | សរុប ( TOTAL ) | |
|---|---|---|---|---|---|---|---|---|---|
| | RICE EXPORTERS | 1 QUARTER | 2 QUARTER | 3 QUARTER | OCT | NOV | DEC | MT | % |
| 1 | BAITANG (KAMPUCHEA) PLC. | 12,331 | 4,292 | 3,818 | 7,535 | 8,218 | 9,322 | 45,516 | 8.40 |
| 2 | CRISTAL RICE (Kampuchea) co., ltd. | 9,598 | 15,110 | 6,610 | 2,365 | 4,745 | 5,372 | 43,800 | 8.08 |
| 3 | KHMER FOODS GROUP CO.,LTD. | 20,872 | 8,185 | 6,788 | 1,931 | 2,767 | 3,247 | 43,790 | 8.08 |
| 4 | NIKOLINE INVESTMENT CO., LTD. | 17,845 | 6,837 | 9,879 | 2,847 | 2,405 | 3,728 | 43,541 | 8.03 |
| 5 | AMRU RICE (CAMBODIA) CO.,LTD | 11,463 | 10,373 | 9,873 | 2,741 | 3,666 | 3,392 | 41,508 | 7.66 |
| 6 | GOLDEN RICE (CAMBODIA) CO.,LTD. | 7,096 | 8,024 | 5,952 | 4,371 | 3,923 | 6,896 | 36,262 | 6.69 |
| 7 | CITY RICE IMPORT EXPORT CO., LTD. | 8,004 | 3,909 | 5,881 | 6,004 | 4,563 | 3,148 | 31,509 | 5.81 |
| 8 | INTERNATIONAL RICE TRADING | 7,709 | 6,872 | 6,099 | 3,174 | 3,195 | 2,298 | 29,347 | 5.41 |
| 9 | T.O.T (TRUST OUR TRADE) CO., LTD. | 7,812 | 4,051 | 4,019 | 1,537 | 1,892 | 718 | 20,029 | 3.69 |
| 10 | SIGNATURES OF ASIA CO.,LTD | 6,521 | 4,264 | 3,815 | 1,531 | 1,116 | 2,037 | 19,284 | 3.56 |
| 11 | APSARA RICE (CAMBODIA) CO., LTD | 3,385 | 4,862 | 2,077 | 1,727 | 2,807 | 1,938 | 16,796 | 3.10 |
| 12 | HUNG HIEP (CAMBODIA) CO., LTD | 3,640 | 1,026 | 2,473 | 4,198 | 745 | 2,623 | 14,705 | 2.71 |
| 13 | SSCORP(CAMBODIA) CO.,LTD | 4,084 | 3,923 | 1,506 | 802 | 1,112 | 884 | 12,311 | 2.27 |
| 14 | W.K.R TRADING CO.,LTD | 3,063 | 2,036 | 1,651 | 1,518 | 1,977 | 1,453 | 11,698 | 2.16 |
| 15 | WHITE GOLD IMPORT EXPORT CO,. LTD. | 2,587 | 2,347 | 715 | 2,049 | 1,994 | 1,543 | 11,235 | 2.07 |
| 16 | GOLDEN DAUN KEO RICE MILL CO., LTD | 4,398 | 2,319 | 663 | 813 | 846 | 892 | 9,931 | 1.83 |
| 17 | INDOCHINA RICE MILL LIMITED | 3,361 | 1,346 | 1,882 | 750 | 852 | 1,527 | 9,718 | 1.79 |
| 18 | LOR EAK HENG SEK MEAS RICE CO., LTD | 3,835 | 2,350 | 3 ,639 | 1,717 | 846 | 300 | 9,048 | 1.67 |
| 19 | Mekong oryza trading co., ltd. | 3,218 | 923 | 714 | 1,300 | 750 | 1,971 | 8,876 | 1.64 |
| 20 | THMOR KORL RICE IMPORT EXPORT CO., LTD | 2,530 | 1,725 | 1,380 | 874 | 1,817 | - | 8,326 | 1.54 |
| 21 | KOL VESSNA investment co., ltd. | - | - | - | 2,400 | 1,700 | 1,942 | 6,042 | 1.11 |
| 22 | CK RICE TRADING CO., LTD. | 1,644 | 641 | 1,172 | 451 | 819 | 475 | 5,202 | 0.96 |
| 23 | GUOHONG (CAMBODIA) INDUSTRY Co.,LTD. | 1,750 | 794 | 327 | 1,150 | 378 | 579 | 4,978 | 0.92 |
| 24 | BATTAMBANG RICE INVESTMENT CO., LTD | 1,102 | 979 | 1,675 | 345 | 400 | 383 | 4,884 | 0.90 |
| 25 | ANGKOR KASEKAM ROONGROEUNG CO.,LTD. | 1,627 | 659 | 1,104 | 216 | 345 | 106 | 4,057 | 0.75 |
| 26 | MEI JING RICE (CAMBODIA) CO., LTD | 248 | 200 | 1,207 | 1,300 | 392 | 600 | 3,947 | 0.73 |
| 27 | LIM KHEANG HOUT IMPORT EXPORT CO., LTD. | 1,029 | 889 | 566 | 199 | 294 | 343 | 3,320 | 0.61 |
| 28 | SOMA TRADING COMPANY LIMITED | 97 | 500 | 2,000 | 500 | - | - | 3,097 | 0.57 |
| 29 | COMMODITY IN FOCUS CO., LTD. | 969 | 525 | 575 | 150 | 450 | 24 | 2,693 | 0.50 |
| 30 | HERBA(Cambodia) co.,ltd | - | - | - | 975 | 756 | 914 | 2,645 | 0.49 |
| 31 | PHOU POY DEVELOPMENT IMPORT EXPORT | 711 | 670 | 580 | 168 | 210 | 145 | 2,484 | 0.46 |
| 32 | Amru and Hanwha international co., ltd | 866 | 642 | 354 | 450 | 42 | 88 | 2,442 | 0.45 |
| 33 | KHY THAY CORPORATION CO.,LTD. | 2,058 | - | - | 230 | - | - | 2,288 | 0.42 |
| 34 | FED RICE BATTAMBANG LTD | 625 | 625 | 425 | 25 | 175 | 245 | 2,120 | 0.39 |
| 35 | CAMBODIAN li shine international trade | 22 | 248 | 758 | 150 | 187 | 346 | 1,711 | 0.32 |
| 36 | ANDURIZ (CAMBODGE) SARL | 1,619 | - | - | - | - | | 1,619 | 0.30 |
| 37 | T T MILLER TECH ( CAMBODIA) CO., LTD | 455 | 265 | - | - | - | 860 | 1,580 | 0.29 |
| 38 | TECH SOON AGRO INDUSTRY CO.,LTD | 25 | 298 | 1,074 | 100 | - | - | 1,497 | 0.28 |
| 39 | BOOST RICHE (CAMBODIA) CO., LTD. | 369 | 289 | 72 | 390 | 375 | - | 1,495 | 0.28 |
| 40 | GLOBAL ECOLOGICAL RICE (CAMBODIA) | 289 | - | - | 31 | 59 | 977 | 1,356 | 0.25 |
| 41 | OVERSEAS FOODS IMPORT EXPORT CO.,LTD | 98 | 462 | 50 | 347 | 197 | 199 | 1,353 | 0.25 |
| 42 | BAYON CEREAL CO., LTD | 420 | 544 | - | 100 | - | 25 | 1,089 | 0.20 |
| 43 | OU TONG DEVELOPMENT (CAMBODIA) | 229 | 192 | 431 | 46 | 93 | 61 | 1,052 | 0.19 |
| 44 | DOMNAK TEUK GROUP CO.,LTD | 240 | 264 | 99 | 72 | - | 98 | 773 | 0.14 |
| 45 | KAMPONG THOM RICE MILL LIMITED. | 125 | 50 | 275 | 125 | 74 | 75 | 724 | 0.13 |
| 46 | VONG BUNHENG IMPORT EXPORT CO., LTD | 489 | 72 | 50 | - | - | - | 611 | 0.11 |
| 47 | GOLDEN STAR Rice Mill | - | - | 48 | 75 | 216 | 202 | 541 | 0.10 |
| 48 | CAPITAL FOOD INVESTMENT IMPORT EXPORT. | 517 | - | - | - | - | - | 517 | 0.10 |
| 49 | AROMA RICE IMPORT EXPORT CO.,LTD | 192 | 96 | 70 | 48 | 46 | 23 | 475 | 0.09 |
| 50 | AIMS GRAIN ASIA LTD. | 92 | 115 | 92 | - | 115 | - | 414 | 0.08 |
| 51 | MUFAVOR INTERNATIONAL (CAMBODIA) INC. | 45 | 111 | 43 | 25 | 134 | - | 358 | 0.07 |
| 52 | HAISUN (CAMBODIA) INVESTMENT | - | 193 | 46 | 68 | - | 48 | 355 | 0.07 |
| 53 | SAHAKREAS CEDAC LTD | 141 | 213 | - | - | - | - | 354 | 0.07 |
| 54 | LK INTERNATIONAL GROUP PLC. | 65 | 110 | 90 | - | 46 | - | 311 | 0.06 |
| 55 | CAMBODIAN organic farm enterprise | - | - | 128 | 31 | 96 | 27 | 282 | 0.05 |
| 56 | UNI-NATURAL CO.,LTD | - | 154 | - | - | 44 | 66 | 264 | 0.05 |
| 57 | CAMBODIAN DIAMOND SEAFOOD & AGRI. | - | - | 2 | 17 | 45 | 160 | 224 | 0.04 |
| 58 | XIANGSHAN RICE (Cambodia) co.,ltd. | 30 | 135 | 46 | - | - | - | 211 | 0.04 |
| 59 | LIM HENG LEAP TRADING CO.,LTD | 150 | - | - | - | - | - | 150 | 0.03 |
| 60 | EANG HEANG IMPORT EXPORT CO.,LTD | - | - | 98 | - | 48 | - | 146 | 0.03 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 61 | BAYON JASMINE RICE CO.,LTD | 48 | 24 | 24 | - | - | 48 | 144 | 0.03 |
| 62 | I.C.RICE (CAMBODIA) CO., LTD | - | - | 125 | - | - | - | 125 | 0.02 |
| 63 | FEED PRO KH CO., LTD | - | 121 | - | - | - | - | 121 | 0.02 |
| 64 | CAM-GRAIN DEVELOPMENT CO., LTD. | 120 | - | - | - | - | - | 120 | 0.02 |
| 65 | SOK KEO IMPORT EXPORT CO., LTD | 24 | 46 | - | - | - | 48 | 118 | 0.02 |
| 66 | Branch of CHONGQING(FT&ECP) GROUP | 100 | - | - | - | - | - | 100 | 0.02 |
| 67 | GREEN RICE AGRICULTURE DEV. | - | 24 | - | - | 73 | - | 97 | 0.02 |
| 68 | GREAT GRAIN & GARMENT | - | - | 92 | - | - | - | 92 | 0.02 |
| 69 | KHUN NGUON rice export co., ltd. | 20 | 20 | 20 | - | - | 20 | 80 | 0.01 |
| 70 | CAVIFOODS co., ltd (Cambodia Vietnam foods) | 72 | - | - | - | - | - | 72 | 0.01 |
| 71 | AGRO INDUST TEXIM | - | - | | | 66 | - | 66 | 0.01 |
| 72 | RICEPADDY FIELDDS (CAMBODIA) CO., LTD. | - | - | 57 | - | - | - | 57 | 0.01 |
| 73 | LBN ANGKOR (CAMPUCHEA) CO., LTD . | - | - | 48 | - | - | - | 48 | 0.01 |
| 74 | MILIN RICE (CAMBODIA) IMPORT EXPORT | 47 | - | - | - | - | - | 47 | 0.01 |
| 75 | JING MI RICE MILL CO., LTD | 46 | - | - | - | - | - | 46 | 0.01 |
| 76 | M.S.C.K. TRADING LIMITED | - | - | - | 23 | 23 | - | 46 | 0.01 |
| 77 | YAMCHANN RICE CO., LTD. | 46 | - | - | - | - | - | 46 | 0.01 |
| 78 | HUA FENG YUAN rice vermicelli | 7 | 18 | 18 | - | - | - | 43 | 0.01 |
| 79 | NGY HENG GROUP CO.,LTD | - | - | 40 | - | - | - | 40 | 0.01 |
| 80 | GLORY trend development limited | - | - | - | - | 34 | - | 34 | 0.01 |
| 81 | BETAMORE LIMITED | - | - | - | 25 | - | - | 25 | 0.00 |
| 82 | JASMINE RICE | | | | | | 22 | 22 | 0.00 |
| 83 | DONG SHUN IMPORT EXPORT CO.,LTD | - | 20 | - | - | - | - | 20 | 0.00 |
| 84 | HUA FENG YUAN RICE VERMICELLI (Cambodia) | - | 18 | - | - | - | - | 18 | 0.00 |
| 85 | PALM RICE | | | | | | 17 | 17 | 0.00 |
| | GRAND TOTAL | 162,220 | 105,970 | 93,315 | 60,016 | 58,168 | 62,455 | 542,144 | 100 |

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១៧

អ្នករៀបចំសរុបទិន្នន័យ

**ឌិន នរិទ្ធ**

**បានឃើញ និង ឯកភាព**

**ប្រធានលេខាធិការដ្ឋាន**

**ច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ**

ឯកឧត្តមបណ្ឌិត **ហ៊ាន វណ្ណហាន**